# អនុក្រឹត្យលេខ ៥៤ អនក្រ .បក ចុះថ្ងៃទី២៨/០៦/១៩៩៤ ស្តីពីកិច្ចសន្យា និងកិច្ចព្រមព្រៀង ពាណិជ្ជកម្ម ឬការខ្ចីបុលដែលទាក់ទងនឹងចំណាយថវិការដ្ឋ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច ព្រះ នរោត្តម សីហនុ វរ្ម័ន នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាស ឱ្យប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤
- យោងព្រះរាជក្រឹត្យ ន.ស.រ.កត.១០៩៤.៨៣ ចុះថ្ងៃទី២៤ ខែតុលា ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- យោងតាមការអនុវត្ត អនុស្សរណៈ ស្តីពីកិច្ចព្រមព្រៀងជាមួយមូលនិធិរូបិយវត្ថុអន្តរជាតិ
- តាមសំណើរបស់ឯកឧត្តមរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

មាត្រា១.-

រាល់កិច្ចសន្យា កិច្ចព្រមព្រៀងពាណិជ្ជកម្ម ឬការខ្ចីបុល ដែលទាក់ទងទៅនឹងចំណាយថវិការដ្ឋ មានតែក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមួយគត់ដែលមានសិទ្ធិសម្រេចនិងចុះហត្ថលេខាលើកិច្ចព្រមព្រៀងទាំងនោះ ។

មាត្រា២.-

បណ្តាក្រសួងពាក់ព័ន្ធទាំងអស់ មានករណីយកិច្ចធ្វើសៀវភៅបន្ទុកផ្នែកបច្ចេកទេស ។ ចំពោះករណីពិសេសក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចអញ្ជើញបណ្តាក្រសួងដែលពាក់ព័ន្ធមកចូលរួមពិភាក្សា ។

មាត្រា ៣.-

រាល់ហត្ថលេខាលើកិច្ចសន្យា និងកិច្ចព្រមព្រៀងខាងលើត្រូវមានការប្រទានសិទ្ធិពីសម្តេចនាយករដ្ឋមន្ត្រីទាំងពីរ ។

មាត្រា ៤.-

សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងរដ្ឋលេខាធិការគ្រប់រដ្ឋលេខាធិការដ្ឋានដែលពាក់ព័ន្ធត្រូវទទួលអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ១៩៩៥

| នាយករដ្ឋមន្ត្រីទី១ | នាយករដ្ឋមន្ត្រីទី២ |
| --- | --- |
| នរោត្តម រណឫទ្ធិ | ហ៊ុន សែន |